ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ..៤១០..គ.ជ.អ.ប..០៣../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី.១៧. ខែ..ធ្នូ..... ឆ្នាំ២០១១.

**គោរពជូន**
**ឯកឧត្តមប្រធានក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីនៃផអ៣**

**កម្មវត្ថុ:** ការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធទិន្នន័យគ្រប់គ្រងបុគ្គលិក (Personnel Database - PDB) របស់ផែនការអនុវត្តរយៈពេល០៣ឆ្នាំ (ផអ៣) ។

**យោង:** ផែនការអនុវត្តរយៈពេល០៣ឆ្នាំ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១១-២០១៣) ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ដើម្បីគាំទ្រដល់កិច្ចដំណើរការអនុវត្តផែនការអនុវត្តរយៈពេល០៣ឆ្នាំដំបូងនៃកម្មវិធីជាតិ និងដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងបុគ្គលិក លេខាធិការដ្ឋានគ.ជ.អ.ប បានរៀបចំ និងសូមដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធទិន្នន័យថ្មីមួយដែលមានឈ្មោះថា ប្រព័ន្ធទិន្នន័យគ្រប់គ្រងបុគ្គលិក (Personnel Database - PDB) ។ ប្រព័ន្ធទិន្ន័យនេះនឹងរក្សាទុកនូវព័ត៌មានទាំងឡាយពាក់ព័ន្ធជាមួយទីប្រឹក្សា មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីទទួលបានចំណាយប្រតិបត្តិការអាទិភាពដែលមានជាអាទិ៍៖ ព័ត៌មានផ្ទាល់ខ្លួន បទពិសោធន៍ការងារ កម្រិតវប្បធម៌ បន្ទុកគ្រួសារ ប្រភេទកិច្ចសន្យា និងការឈប់សម្រាកជាដើម ។

ក្នុងគោលបំណងពង្រឹងនូវប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ទីប្រឹក្សាម្នាក់ៗ លេខាធិការដ្ឋាន គ.ជ.អ.ប សូមដាក់ចេញនូវគោលការណ៍ និងនីតិវិធីមួយចំនួនដូចខាងក្រោម ៖

- យោងតាមលក្ខខណ្ឌការងារ ទីប្រឹក្សាម្នាក់ៗត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារប្រចាំខែរបស់ខ្លួន និងដាក់ជូនទៅប្រធានក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីនីមួយៗ ដើម្បីស្នើសុំការពិនិត្យ និងបញ្ជាក់យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែនីមួយៗ ។ ទីប្រឹក្សាដែលបរិយាយនៅក្នុងសេចក្តីណែនាំនេះ សំដៅដល់ទីប្រឹក្សាថ្នាក់ជាតិនៃអនុកម្មវិធីនីមួយៗ ។
- បន្ទាប់ពីទទួលបាននូវការឯកភាពយល់ព្រមលើរបាយការណ៍ពីប្រធានក្រុមការងារគ្រប់គ្រងនិងអនុវត្តអនុកម្មវិធីរួចមក មន្ត្រីបច្ចេកទេសរដ្ឋបាលត្រូវទទួលខុសត្រូវបញ្ចូលព័ត៌មានទាំងនេះទៅក្នុងទម្រង់បែបបទសង្ខេបស្តីពីចលនាបុគ្គលិក (Staff Movement Report) ដែលទម្រង់នេះនឹងត្រូវផលិតចេញពី

ប្រព័ន្ធ PDB និងដោយមានការចុះហត្ថលេខាទទួលស្គាល់ពីប្រធានក្រុមការងារសាមី រួចបញ្ជូនមក លេខាធិការដ្ឋាន គ.ជ.អ.ប **ឲ្យបានមុនថ្ងៃទី២៣ នៃខែនីមួយៗ** ។

- លេខាធិការដ្ឋាននឹងធ្វើការទូទាត់ប្រាក់បៀវត្សរ៍ទាំងនោះនៅរៀងរាល់ថ្ងៃធ្វើការចុងក្រោយនៃខែនីមួយៗ តាមរយៈគណនីធនាគាររបស់ទីប្រឹក្សា មន្ត្រីកិច្ចសន្យា និងមន្ត្រីទទួលបានចំណាយប្រតិបត្តិការអាទិភាពម្នាក់ៗ ដោយផ្អែកតាមទិន្នន័យដូចមានចែងនៅក្នុងទម្រង់ស្តីពីចលនាបុគ្គលិកដែលទទួលបានពីអនុកម្មវិធីនីមួយៗ ។
- មន្ត្រីបច្ចេកទេសរដ្ឋបាល ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង ថែរក្សា និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យនេះឲ្យបានត្រឹមត្រូវនិងជាប្រចាំ ជាពិសេសការផ្លាស់ប្តូរព័ត៌មានគណនីធនាគារ ការប្រែប្រួលចំនួនអ្នកនៅក្នុងបន្ទុកគ្រួសារ និងច្បាប់ឈប់សម្រាកជាដើម ។
- មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីទទួលបានចំណាយប្រតិបត្តិការអាទិភាពមិនត្រូវបានភ្ជាប់នៅក្នុងលក្ខខណ្ឌនៃការរៀបចំរបាយការណ៍ដូចបានជម្រាបជូនខាងលើនេះឡើយ។ ប៉ុន្តែ ចំពោះមន្ត្រីទទួលបានចំណាយប្រតិបត្តិការអាទិភាពត្រូវមានរបាយការណ៍ប្រចាំខែស្តីពីលទ្ធផលការងារដោយប្រើប្រាស់ទម្រង់ដោយឡែកមួយដែលតម្រូវដោយគោលការណ៍ណែនាំស្តីពីចំណាយប្រតិបត្តិការអាទិភាព។
- ប្រព័ន្ធទិន្នន័យគ្រប់គ្រងបុគ្គលិកនេះនឹងត្រូវអនុវត្តចាប់ពី**ខែមករា ឆ្នាំ២០១២ ខាងមុខនេះតទៅ**។ ពាក់ព័ន្ធនឹងបញ្ហានេះលេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំបើកគណនីប្រើប្រាស់ PDB ដល់មន្ត្រីទទួលបន្ទុកប្រើប្រាស់ក្នុងពេលឆាប់ៗនេះ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តការងារប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

សូមជូនភ្ជាប់មកជាមួយនូវទម្រង់បែបបទសង្ខេបស្តីពីចលនាបុគ្គលិក ទម្រង់របាយការណ៍របស់ទីប្រឹក្សា និងទម្រង់របាយការណ៍ប្រចាំខែស្តីពីលទ្ធផលការងារ ដោយប្រើប្រាស់ទម្រង់ដោយឡែកមួយដែលតម្រូវដោយគោលការណ៍ណែនាំស្តីពីចំណាយប្រតិបត្តិការអាទិភាព។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**ប្រធាន**

**ង៉ែត ចំរើន**